**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
លេខៈ ០៩៤/២២ អអរ

# សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្តរបស់រដ្ឋបាលរាជធានីភ្នំពេញ"

ព្រឹកថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **"វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្តរបស់រដ្ឋបាលរាជធានីភ្នំពេញ"** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ម៉ប់ សារិន ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ**
- **លោកស្រី ប្រាក់ ម៉ាលី ចៅសង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបំផុស និងបង្ហាញជាសាធារណៈ នូវយន្តការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាប្រវត្តិសាស្ត្ររបស់កម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងកិច្ចរក្សាបាននូវការជឿទុកចិត្ត ចូលរួម និងគាំទ្រពីប្រជាពលរដ្ឋ តាមយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន។**

## I. សេចក្តីផ្តើម

រាជធានីភ្នំពេញ គឺចែកចេញជា ១៤ខណ្ឌ ស្មើនឹង ១០៥សង្កាត់ មានប្រជាជនរស់នៅអចិន្ត្រៃយ៍ចំនួន ២,២៨ លាននាក់ និងមានប្រជាជនស្នាក់នៅបម្រើការងារប្រមាណជិត ១លាននាក់។

## II. វឌ្ឍនភាពការងារ

❖ **ក្រុមប្រឹក្សារាជធានី**

រដ្ឋបាលរាជធានីភ្នំពេញ បានអនុវត្តទៅតាមប្លង់គោលប្រើប្រាស់ដីឆ្នាំ២០៣៥, ផែនការអភិវឌ្ឍប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងតាមគោលការណ៍ណែនាំរបស់ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ក្រសួងមហាផ្ទៃ និងក្រសួង-ស្ថាប័នថ្នាក់ជាតិ។ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ, ក្របខ័ណ្ឌគតិយុត្ត, បទបញ្ញា និងលិខិតបទដ្ឋានជាធរមាន ក្រុមប្រឹក្សារាជធានី សម្រេចបានការងារសំខាន់ៗ រួមមាន៖

- បានរៀបចំកិច្ចប្រជុំសាមញ្ញ សរុបបានចំនួន ៣១លើក, វិសាមញ្ញ ៣លើក, សម្ងាត់ ២លើក និងកិច្ចប្រជុំនានារបស់គណៈកម្មាធិការជំនាញ
- បានអនុវត្តនូវគោលនយោបាយ និងសេចក្តីណែនាំផ្សេងៗ ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធប្រឡាយ-លូ បណ្តាញទឹកស្អាត បណ្តាញអគ្គិសនីសាធារណៈ ទូរគមនាគមន៍ ការកែលម្អសួនច្បារសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រជាច្រើនទៀត ព្រមទាំងយន្តការឆ្លើយតបចំពោះគ្រោះមហន្តរាយ និងជំងឺឆ្លងនានា ពិសេសគឺជំងឺកូវីដ-១៩
- បានអនុវត្តគម្រោងសកម្មភាពនៃកម្មវិធីវិនិយោគក្នុងនោះ រដ្ឋបាលរាជធានីភ្នំពេញមាន ១៤២ គម្រោង, មន្ទីរ-អង្គភាពជុំវិញរដ្ឋបាលរាជធានីភ្នំពេញ មាន ១០៩គម្រោង, រដ្ឋបាលខណ្ឌ-សង្កាត់ មាន ៤២៣គម្រោង និងបានអនុវត្តនីតិវិធីលទ្ធកម្មសរុបចំនួន ៩៦គម្រោង
- បានខិតខំតម្រង់ទិស និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងដំណើរការអនុវត្តតួនាទី និងភារកិច្ចរបស់មន្ត្រី និងបុគ្គលិក ដើម្បីបង្ខិតសេវាសាធារណៈ ឱ្យកាន់តែកៀកជិតប្រជាពលរដ្ឋ
- បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ដែលការជួបពិភាក្សារវាងក្រុមការងារថ្នាក់ជាតិ ក្រុមប្រឹក្សារដ្ឋបាលគ្រប់ជាន់ថ្នាក់ ជាមួយនឹងប្រជាពលរដ្ឋ ដើម្បីទទួលបាននូវមតិយោបល់ បញ្ហា និងសំណើសំណូមពរ ព្រមទាំងការដោះស្រាយជូនប្រជាពលរដ្ឋ
- បានគាំទ្រដល់រដ្ឋបាលខេត្ត ក្នុងយុទ្ធនាការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋ។

❖ **សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង**

សង្កាត់បឹងកេងកងទី១ មានប្រជាជនសរុប ៩៤៣ គ្រួសារ ស្មើនឹង ៥៦៦២នាក់ ស្រី ២៥៤៩ នាក់។ សមាជិកក្រុមប្រឹក្សាសង្កាត់សរុប ចំនួន ៩ នាក់ (ស្រី ៦នាក់)។ សង្កាត់នេះ មានសក្តានុពលទាំងសេដ្ឋកិច្ច សង្គមកិច្ច វិស័យទេសចរណ៍ មានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ប្រព័ន្ធលូ ផ្សាររដ្ឋ និងផ្សារឯកជន (ផ្សារទំនើប) សាលារៀនរដ្ឋ និងឯកជន វត្តអារាម មន្ទីរពេទ្យឯកជន ព្រមទាំងអគារអាផាតមិន

និងអគារខុនដូរខ្ពស់ៗ ជាច្រើនដែលកំពុងរីកលូតលាស់។ រដ្ឋបាលសង្កាត់ បានសម្រេចនូវវឌ្ឍនភាពសំខាន់ៗ រួមមាន៖

- បានរៀបចំវេទិកាសាធារណៈ(មុនការរីករាលដាលនៃជំងឺកូវីដ-១៩) និងបានចុះសួរសុខទុក្ខតាមខ្នងផ្ទះវិញ ព្រមទាំងបានចុះផ្សព្វផ្សាយពីវិធានការការពារជំងឺកូវីដ-១៩ ដោយបានចែកខិតប័ណ្ណ អាល់កុល ម៉ាស និងបានទទួលសំណូមពររបស់ប្រជាពលរដ្ឋ ដើម្បីធ្វើការដោះស្រាយ
- បានចុះរៀបចំសណ្តាប់ធ្នាប់ និងរៀបចំកម្លាំងចុះល្បាតតាមផ្លូវ តាមផ្ទះសំណាក់ សណ្ឋាគារ បន្ទប់ជួល ព្រមទាំងបានផ្សព្វផ្សាយឱ្យមានការចូលរួមសហការផ្តល់ព័ត៌មានពីប្រជាពលរដ្ឋ អំពីបទល្មើស និងសកម្មភាពអសន្តិសុខផ្សេងៗ ដើម្បីធ្វើឱ្យមូលដ្ឋានសង្កាត់មាន សន្តិសុខ និងសុវត្ថិភាព កាន់តែល្អប្រសើរឡើង
- បានកសាងហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ ដោយការប្រើប្រាស់ថវិកាវិភាជន៍ពីរាជរដ្ឋាភិបាល និងការចូលរួមរបស់បងប្អូនប្រជាពលរដ្ឋ សប្បុរសជន បានប្រែក្លាយពីផ្លូវគ្រួសក្រហម ទៅជាផ្លូវកៅស៊ូបេទីមទាំងអស់ សរុបចំនួន ២៥ខ្សែ មានបណ្តាញលូត្រឹមត្រូវ ដែលធ្វើឱ្យការលិចលង់នារដូវវស្សាត្រូវបានកាត់បន្ថយ
- បានយកចិត្តទុកដាក់ជាប់ជាប្រចាំ លើការផ្តល់សេវាសាធារណៈ ដូចជាការចុះសំបុត្រមរណភាព សំបុត្រអាពាហ៍ពិពាហ៍ អត្តសញ្ញាណប័ណ្ណ និងការធ្វើលិខិតស្នាមផ្សេងៗ ព្រមទាំងបានបង្កើតក្រុមការងារដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងការរង់ចាំទទួល និងដោះស្រាយនូវពាក្យបណ្តឹងរបស់បងប្អូនប្រជាពលរដ្ឋ ឱ្យបានទាន់ពេលវេលា
- បានចុះធ្វើការអប់រំផ្សព្វផ្សាយចំណេះដឹង និងចេះទប់ស្កាត់ ស្តីពីជំងឺឆ្លងគ្រប់ប្រភេទ និងបានសហការចុះចាក់ថ្នាំបង្ការជូនដល់កុមារ និងស្ត្រីមានផ្ទៃពោះ រួមទាំងប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងបានចូលរួមប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ បានខិតខំស្វះស្វែងរកវ៉ាក់សាំង ផ្តល់ជូនប្រជាពលរដ្ឋ។

## III. ទិសដៅការងារបន្ត

### ❖ ក្រុមប្រឹក្សារាជធានី

ក្រុមប្រឹក្សារាជធានី បានដាក់ចេញនូវទិសដៅការងារបន្ត រួមមាន៖

- បន្តចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្ការ ទប់ស្កាត់ និងគ្រប់គ្រងស្ថានភាព ការរីករាលដាលនៃជំងឺកូវីដ-១៩
- បន្តបង្កើនការយកចិត្តទុកដាក់អនុវត្តគោលនយោបាយ "ភូមិ-សង្កាត់ មានសុវត្ថិភាព" ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ

- បន្តរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ នៅតាមបណ្តាមូលដ្ឋាន ដើម្បីបង្កើតឱកាសឱ្យមានការជួបពិភាក្សារវាងក្រុមការងារថ្នាក់ជាតិ ក្រុមប្រឹក្សារដ្ឋបាលគ្រប់ជាន់ថ្នាក់ ជាមួយនឹងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ច ដើម្បីទទួលបាននូវមតិយោបល់ ការព្រួយបារម្ភ និងសំណើសំណូមពរនានាក្នុងមូលដ្ឋាន
- បន្តជំរុញការផ្តល់សេវាសាធារណៈតាម អង្គភាពច្រកចេញចូលតែមួយរាជធានីភ្នំពេញ ការិយាល័យច្រក ចេញចូលតែមួយខណ្ឌ និងយន្តការច្រកចេញចូលតែមួយសង្កាត់ ឱ្យបានល្អប្រសើរជូនប្រជាពលរដ្ឋ ដើម្បីចូលរួមលើក កម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងចូលរួមលើកកម្ពស់ការអនុវត្តកំណែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាព។
- បន្តពង្រឹងតួនាទី និងភារកិច្ចរបស់ ការិយាល័យប្រជាពលរដ្ឋរាជធានីភ្នំពេញ ដើម្បីចូលរួមលើកកម្ពស់ អភិបាលកិច្ចល្អក្នុងការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បន្តពង្រឹងការងារគ្រប់គ្រងសំរាម និងសំណល់រឹងគ្រប់ប្រភេទក្នុងរាជធានីភ្នំពេញ
- បន្តជំរុញ និងគាំទ្រការអនុវត្តក្របខណ្ឌការងារគណនេយ្យភាពសង្គម និងគេហទំព័រផ្លូវការរបស់រដ្ឋបាលរាជធានីភ្នំពេញ សម្រាប់ទទួលយកនូវមតិយោបល់ពីសាធារណជនតាមប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គម និងដោះស្រាយ ឱ្យទាន់ពេលវេលា ឆាប់រហ័ស តម្លាភាព ប្រសិទ្ធភាព ភាពជឿទុកចិត្ត និងគណនេយ្យភាពខ្ពស់។

❖ **សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង**

- បន្តខិតខំរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គមឱ្យបានកាន់តែល្អប្រសើរ
- បន្តអនុវត្តយ៉ាងម៉ឺងម៉ាត់គោលនយោបាយភូមិ-សង្កាត់ មានសុវត្ថិភាព ដើម្បីជានា និងលើកកម្ពស់ការចូលរួម យ៉ាងសកម្មរបស់ប្រជាពលរដ្ឋ ក្នុងការបង្កទប់ស្កាត់ និងលុបបំបាត់បទល្មើសនានា ពិសេសអំពើលួច ឆក់ ប្លន់ គ្រប់ ប្រភេទ ការផលិតចែកចាយ ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ អំពើអនាចារ ការជួញដូរស្ត្រី និងកុមារ
- បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថ្មីបន្ថែមទៀតដោយប្រើប្រាស់មូលនិធិសង្កាត់ និងមូលនិធិគាំទ្ររបស់រដ្ឋបាលខណ្ឌបឹងកេងកង
- បន្តយកចិត្តទុកដាក់លើការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ឱ្យកាន់តែល្អប្រសើរបន្ថែមទៀត ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងទាន់ពេលវេលា

- បន្តដោះស្រាយ និងឆ្លើយតប នូវរាល់សំណើ សំណូមពរផ្សេងៗ របស់បងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋានសង្កាត់ ឱ្យបានកាន់តែល្អប្រសើរ និងទាន់ពេលវេលា
- បន្តផ្សព្វផ្សាយប្រជាពលរដ្ឋក្នុងមូលដ្ឋាន អោយមានការយល់ដឹងពីការគ្រប់គ្រប់ ទុកដាក់សំរាម អោយបាន ត្រឹមត្រូវ ដើម្បីធានាថាក្នុងមូលដ្ឋានសង្កាត់ ជាមូលដ្ឋានដែលមានអនាម័យ និងបរិស្ថានល្អ
- បន្តយកចិត្តទុកដាក់ពង្រឹង សមាគមមនុស្សចាស់ដែលមានស្រាប់ និងពង្រឹងសេវាគាំទ្រដល់ចាស់ជរា ពិសេសជនចាស់ជរា ក្រីក្រ គ្មានទីពឹង ដោយធានាពុំឱ្យមានជនចាស់ជរាណាមួយ ពុំបានទទួលការគាំពារនោះឡើយ
- លើកកម្ពស់ការចូលរួមស្ត្រី និងយុវជនឱ្យកាន់តែទូលំទូលាយ ក្នុងការធ្វើសេចក្តីសម្រេចចិត្តទាំងក្នុងសង្គម គ្រួសារ នយោបាយ និងការអភិវឌ្ឍសង្កាត់ប្រកបដោយនិរន្តភាព និងសមធម៌។

## IV. សម្គាល់

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានខិតខំប្រឹងប្រែងក្នុងការផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋ បច្ចុប្បន្ននេះ បានពង្រីកផ្ទៃដីបាន ជិត៧០០គីឡូម៉ែត្រការ៉េ ដែលមានសមត្ថភាពផលិតទឹកបាន ៥៩២ពាន់ម៉ែត្រគូប ក្នុងមួយថ្ងៃ ចេញពីរោងចក្រចំនួន ៤គឺ រោងចក្រភូមិព្រែក និរោធ ជ្រោយចង្វា និងរោងចក្រចំការមន ដែលមានបណ្តាញផ្គត់ផ្គង់ប្រមាណជាង ៣៨៥០គីឡូម៉ែត្រ គ្របដណ្តប់ ៩២% ទូទាំងរាជធានីភ្នំពេញ។ តាមរយៈការសិក្សានៃអ្នកជំនាញបានធ្វើការប៉ាន់ស្មានថា ក្នុងឆ្នាំ២០២២នេះ តម្រូវការទឹកប្រើប្រាស់ក្នុងមួយថ្ងៃគឺប្រមាណ ៨០០ពាន់ម៉ែត្រគូប លើសសមត្ថភាពផលិត ដូច្នេះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានជំរុញឱ្យរោងចក្រផលិតទឹកលើសសមត្ថភាពផលិតបានជាង ៦៣៥ពាន់ម៉ែត្រគូប។ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានអំពាវនាវឱ្យប្រជាពលរដ្ឋទាំងអស់ចូលរួមក្នុងការសន្សំសំចៃទឹក នៅក្នុងរដូវប្រាំងនេះ ដើម្បីឱ្យមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ និងបានប្តេជ្ញាថា នៅចុងឆ្នាំ២០២៣ ប្រជាជននឹងមានទឹកស្អាតប្រើប្រាស់ ១០០% ហើយនៅដើមឆ្នាំ២០២៤ នឹងធានាបានលែងមានបញ្ហាខ្វះខាតទឹកកើតមានទៀតឡើយ។

ថ្ងៃអង្គារ ១៣រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២